# ព្រះរាជក្រឹត្យ

នស/រកត/០៣០៩/២៤៣

## ស្តីពី

## ការកែសម្រួលមាត្រា១៣ និងមាត្រា៣០ នៃព្រះរាជក្រឹត្យ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា និង ការកែសម្រួលមាត្រា១១ថ្មី នៃព្រះរាជក្រឹត្យ ស្តីពីការកែសម្រួលមាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៥ និងមាត្រា១៦ នៃព្រះរាជក្រឹត្យ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/ ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០០៥ ស្តីពីការកែសម្រួមាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៥ និងមាត្រា១៦ នៃព្រះរាជក្រឹត្យ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា

- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្ត នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រាមួយ.-**

មាត្រា១៣ និងមាត្រា៣០ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា ត្រូវបានកែសម្រួល ដូចខាងក្រោម ៖

**មាត្រា១៣ថ្មី.-**

សមាជិក **គ.ឧ.ក** មានអាណត្តិបីឆ្នាំ ហើយអាចត្រូវជ្រើសតាំងបន្តរយៈពេលបីឆ្នាំទៀតបាន តាមរយៈការតែងតាំង ឬ តាមរយៈការបោះឆ្នោត ដែលអនុវត្តតាមនីតិវិធីកំណត់ក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៥ និងមាត្រា១៦ នៃព្រះរាជក្រឹត្យ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា ។

**មាត្រា៣០ថ្មី.-**

ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ត្រូវមានមុខវិជ្ជា ដែលស្រង់ចេញពីវិស័យសិក្សាទាំងបួនផ្នែក ដូចខាងក្រោម ៖

- សិល្បៈ និងមនុស្សសាស្ត្រ
- គណិតសាស្ត្រ វិទ្យាសាស្ត្រ និងកុំព្យូទ័រវិទ្យា
- វិទ្យាសាស្ត្រសង្គម
- ភាសាបរទេស

ចំនួនក្រេឌីតនៃមុខវិជ្ជាក្នុងវិស័យនីមួយៗ ត្រូវមានយ៉ាងតិច១០ភាគរយនៃពិន្ទុក្រេឌីតសរុប សម្រាប់វិញ្ញាបនបត្រថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន។ មុខវិជ្ជាដែលនិស្សិតជ្រើសរើសនៅក្នុងឆ្នាំសិក្សាមូលដ្ឋាន ត្រូវស្របទៅនឹងផ្នែកជំនាញដែលនិស្សិតជ្រើសរើស ប៉ុន្តែនិស្សិតត្រូវតែសិក្សាមុខវិជ្ជាចាំបាច់ សម្រាប់ការចូលសិក្សានៅថ្នាក់បរិញ្ញាបត្រ ។

**មាត្រាពីរ.-**

មាត្រា១១ថ្មី នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៥ និងមាត្រា១៦ នៃព្រះរាជក្រឹត្យ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា ត្រូវបានកែសម្រួល ដូចខាងក្រោម ៖

ROYAUME DU CAMBODGE

មាត្រា១១ថ្មីស្ទួន.-

សមាជិក គ.ឧ.ក ទាំងអស់ត្រូវជ្រើសតាំងឱ្យបំរើការងារមិនពេញម៉ោង និង ទទួលប្រាក់ឧបត្ថម្ភតាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី ។ ប្រាក់ឧបត្ថម្ភ របស់សមាជិក គ.ឧ.ក ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់ប្រធាន គ.ឧ.ក ។

គ.ឧ.កមានអគ្គលេខាធិការដ្ឋានមួយចំណុះផ្ទាល់ទីស្តីការគណៈរដ្ឋមន្ត្រី។ អគ្គលេខាធិការដ្ឋាន គ.ឧ.ក ដឹកនាំដោយអគ្គលេខាធិការ១រូប និងអមដោយអគ្គលេខាធិការរងមួយចំនួន ជាជំនួយការតាមការចាំបាច់។ អគ្គលេខាធិការ និងអគ្គលេខាធិការរង ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។ សមាសភាព ការរៀបចំ និងការប្រព្រឹត្តទៅ របស់អគ្គលេខាធិការដ្ឋាននៃ គ.ឧ.ក នឹងកំណត់ដោយអនុក្រឹត្យ ។

គ.ឧ.ក មានបទបញ្ជាផ្ទៃក្នុង រូបសញ្ញា និង ត្រាមួយ ដោយឡែករបស់ខ្លួន ។

**មាត្រាបី.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រាបួន.-**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ។

**មាត្រាប្រាំ.-**

ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៩

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

នស/រកត/០៣០៩/២៤៦ **នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ: ៧១៥ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ២០០៩

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុំ ម៉ានិត**

ដោយ

**ចិនកេន**

7/4 ru